ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ...៣២៧/១១......ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម "ប.ស.ស" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម មានកិត្តិយសសូមជម្រាប ម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ឲ្យបានជ្រាបថា ប.ស.ស បានបង្កើតលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hotline) ២៤ ម៉ោង ដែលមានលេខទំនាក់ទំនង ១២៨៦ ដែលអាចហៅចូលបានគ្រប់ប្រព័ន្ធ សម្រាប់ផ្តល់សេវាសង្គ្រោះបន្ទាន់ដល់កម្មករនិយោជិត ដែលជាសមាជិក ប.ស.ស ទទួលរងនូវគ្រោះថ្នាក់ការងារ ។

ដើម្បីបម្រើផលប្រយោជន៍បងប្អូនកម្មករនិយោជិត ជាសមាជិក ប.ស.ស សូមលោក លោកស្រីម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាន មេត្តាជួយផ្សព្វផ្សាយលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hotline) ២៤ ម៉ោង ដែលមានលេខ ១២៨៦ ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាននឹងចូលរួមផ្សព្វផ្សាយតាមស្មារតីនៃសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០១១

អគ្គនាយក

អ៊ុក សមវិទ្យា